# ជូនចំពោះប្រិយមិត្តទាំងឡាយ

ព្រះវរបិតាសួគ៌មានបន្ទូលមកកាន់យើងតាមរយៈពួកព្យាការីរបស់ទ្រង់ ។ ហើយនៅខែមុន យើងបានស្តាប់ពួកព្យាការី និងពួកសាវកនៅក្នុងសន្និសីទទូទៅ! ពាក្យពេចន៍ដែលយើងបានស្តាប់នៅ ក្នុងសន្និសីទទូទៅគឺមានសារៈសំខាន់ចំពោះយើងទាំងអស់គ្នា ។ ពាក្យពេចន៍ទាំងនោះប្រាប់យើងពីរបៀបដើម្បីប្រែក្លាយកាន់តែដូចជាព្រះយេស៊ូវគ្រីស្ទ ។

តើផ្នែកណាដែលអ្នកចូលចិត្តនៅក្នុងសន្និសីទ ? ចូលទៅកាន់ ទំព័រទី ២ ដើម្បីអានសារលិខិតពិសេសមួយមកពីព្យាការី!

ដោយក្តីស្រឡាញ់
ទស្សនាវដ្តី *ប្រិយមិត្ត*



### តើខ្ញុំជានរណា?

យើងលេងល្បែង កំសាន្ត « តើខ្ញុំជានរណា ? » ហើយចូលចិត្តវា ( ខែ មិថុនា ឆ្នាំ ២០២០ ) ! សូមអរគុណសម្រាប់ល្បែងសប្បាយៗ និងដំណើររឿងល្អៗ ! យើងក៏ចូលចិត្តស្តាប់ដំណើររឿងក្នុងទស្សនាវដ្តី *ប្រិយមិត្ត* ជាសំឡេង ខណៈពេលយើងកំពុងទទួលទានអាហារដែរ ។ វាជួយយើងឲ្យមានព្រះវិញ្ញាណនៅក្នុងគេហដ្ឋានរបស់យើង ។

**វ៉ាលីនថាន និង ជូលី ភី អាយុ ៤ ឆ្នាំ និង ៦ ឆ្នាំ រស់នៅ រដ្ឋ អារីហ្សូណា ស.រ.អា.**



### យើងចូលចិត្តមើលព្រះវិហារបរិសុទ្ធ

ឡាស៍, ម៉ារីន និង លីវ៉ា ប៊ី អាយុ ៦ ឆ្នាំ, ១១ ឆ្នាំ និង ៣ ឆ្នាំបានទៅព្រះវិហារបរិសុទ្ធ ផ្លូវ ផល មីនីសូតា។



### កន្លែងដែលយើងអានទស្សនាវដ្តី *ប្រិយមិត្ត*

ប្អូនប្រុស ម៉ាសេលកូ និង អាឡេវ៉ាន់ត្រូ អេ អាយុ ៦ ឆ្នាំ និង ៣ ឆ្នាំ អានទស្សនាវដ្តី *ប្រិយមិត្ត* ជាភាសាអេស្ប៉ាញ រស់នៅ នូវ៉ឺ លីអូន ប្រទេស ម៉ិកស៊ិក!